# ក្រសួងយុវជន ខោនធី Washington

ច្បាប់អន្តោប្រវេសន៍សហព័ន្ធថ្មីៗនេះ

ការបង្កើតច្បាប់អន្តោប្រវេសន៍សហព័ន្ធ នៅបន្តបង្កើតភាពមិនប្រាកដ សំរាប់សហគមន៍ រដ្ឋ Oregon ជាពិសេស មានកង្វល់ ស្តីពីបទបញ្ជាប្រតិបត្តិ នៃខែមករា 2017 ផ្លាស់ប្តូររបៀបនៃការប្រតិបត្តិច្បាប់ នៅក្នុងខោនធី Washington។ **ខណៈវាជាសារៈសំខាន់ ដើម្បីដោះស្រាយការល្មើសច្បាប់ ខោនធី Washington និងក្រសួងយុវជន ត្រូវបានហាមឃាត់ ពីការប្រតិបត្តិតាមបទបញ្ជាប្រតិបត្តិ ដែលបានថ្លែង។** ច្បាប់រដ្ឋ Oregon និងតុលាការមណ្ឌលសហព័ន្ធ ហាមឃាត់ការប្រតិបត្តិច្បាប់ តាមតំបន់ ពីការគោរពតាមសំណើដីកាឃុំខ្លួននៃក្រសួង អន្តោប្រវេសន៍ និងប្រតិបត្តិការគយ (Immigration and Customs Enforcement, ICE)។

បេសកកម្មនៃក្រសួងយុវជន ខោនធី Washington គឺដើម្បីការពារសាធារណជន តាមការកាត់បន្ថយនូវការប្រព្រឹត្តិល្មើសច្បាប់ ដើម្បីកសាងជនរងគ្រោះ ដែលបានរងទុក្ខវេទនា ពីការប្រព្រឹត្តិល្មើសច្បាប់ និងប្រើការអនុវត្តន៍ដោយប្រសិទ្ធិភាព ដើម្បីបង្រៀនយុវជន ឲ្យមានកិរិយាដែលទទួលខុសត្រូវ។ ខណៈយើងចូលប្រឡូកក្នុងការងាររបស់យើង នោះយើងក៏បានប្តេជ្ញាចិត្ត ដើម្បីឲ្យប្រាកដថាទាំងអស់គ្នា នៃសមាជិកសហគមន៍របស់យើង ដោយមិនប្រកាន់ ជាតិសាសន៍ ពណ៌សំបុរ ភេទ ដើមកំណើត សាសនា ឬស្ថានភាពអ្វីផ្សេងទៀតដែលបានការពារ មានឱកាសស្មើៗគ្នា ចំពោះនីតិវិធីយុត្តិធម៌ ព្រមទាំងសេវា និងការគាំទ្ររបស់យើង។ ឧទាហរណ៍ ក្រសួងយុវជន ខោនធី Washington ឲ្យតម្លៃដល់ឱកាសដោយឥតល័ក្ខខ័ណ្ឌ ចំពោះយុត្តិធម៌ សំរាប់ជនរងគ្រោះទាំងអស់ នៃឧក្រិដ្ឋកម្មយុវជន។ ស្រដៀងគ្នានេះដែរ យុវជនទណ្ឌិតទាំងអស់ មានឱកាសចំពោះការអប់រំ និងការព្យាបាលសមរម្យ នៅក្នុងសហគមន៍របស់យើង។ សមាជិកគ្រួសារ អាចទុកចិត្តថាគេនឹងបានសុខ នៅក្នុងអាគារ និងសហគមន៍របស់យើង។ យើងនឹងបន្តធ្វើការ ដើម្បីពង្រឹងកំឡាំងគ្រួសារទាំងអស់ នៃសមាជិកសហគមន៍របស់យើង ត្បិតយើងមានឯកសិទ្ធិ ដើម្បីធ្វើការដ៏សំខាន់នេះ។

*Rev. 04/23*

**ក្រសួងយុវជន (Juvenile Department)**
222 N First Avenue, MS 47 · Hillsboro, OR 97124-3000
ទូរស័ព្ទ៖ (503) 846-8861 · ទូរសារ៖ (503) 846-8886 · TTY: 711 · www.washingtoncountyor.gov/juvenile